ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៣២៤ ១៨·រ៉ាក អ.សសក

# សេចក្តីសម្រេច
# ស្តីពី
# សមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែនិងថាមពល
# សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៧៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ ១ ._**

ត្រូវបានចាត់តាំងសមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែនិងថាមពល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភាដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម | **យស មុនីរ៉ាត់** | អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ |
| ២- ឯកឧត្តម | **វិចទ័រ ហ្ស៊ូនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល |
| ៣- ឯកឧត្តម | **ជៀប សួរ** | អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត |

**ប្រការ ២ ._**

ក្រុមអ្នកនាំពាក្យនេះមានភារកិច្ចដូចតទៅ៖

- ទាក់ទង និងឆ្លើយឆ្លងជាផ្លូវការជាមួយសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ

- សហការជាមួយអង្គភាពចំណុះក្រសួងរ៉ែនិងថាមពល ដើម្បីប្រមូលព័ត៌មាន និងឯកសារដែលពាក់ព័ន្ធនឹងមូលដ្ឋានក្នុងការឆ្លើយបំភ្លឺជាមួយសាធារណជន និងសារព័ត៌មាននានា
- រាយការណ៍រាល់ការស្រាយបំភ្លឺទាំងឡាយណាក្នុងនាមក្រសួងជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចដទៃទៀតតាមការចាត់តាំងរបស់រដ្ឋមន្ត្រី។

**ប្រការ ៣ .-**

សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងរ៉ែនិងថាមពល
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ